ការសម្ភាសន៍របស់ ស៊ុំ លន

ក៖ អ្នកដែលសម្ភាសន៍ សំ រីឌីន ខ៖ អ្នកដែលត្រូវបានសម្ភាសន៍ ស៊ូ លន

<u>ប្រវត្តិរូបសង្ខេបរបស់ ស៊ុំ លន</u>

ឈ្មោះ ពេជ្ស ស្រីពៅ ឈ្មោះក្រៅ ពៅ អាយុ ៥៥ឆ្នាំ ឆ្នាំកំណើត ១៩៧៤
ទីកន្លែងកំណើតនៅ ភូមិ ក្រឡា ឃុំ អំពិល ស្រុក កំពង់សៀម ខេត្ត កំពង់ចាម
ទីលំនៅបច្ចុប្បន្ន នៅផ្ទះជួលច្បារអំពៅ មុខរបរ លក់បាយ និង ប្រហិត ឪពុកឈ្មោះ ត្រិល ពេជ្រ ម្តាយឈ្មោះ ឆ្លង រៀម មុខរបរ កសិករ។

ក៖ ជាដំបូងខ្ញុំបាទសូមជំរាបសួរអ្នកមីញ ខ្ញុំបាទឈ្មោះ សំ រីឌីន
ដំណាងអោយសកលវិទ្យាល័យ ប៊ីវ៉ាយយ៉ូ
សហរដ្ឋអាមេរិក។ដែលចុះមកផ្ទាល់ដើម្បីធ្វើការសម្ភាសន៍ពាក់ព័ន្ធនឹងភូមិប្រវត្តិផ្ទាល់របស់ប្រជាពលរដ្ឋខ្មែរ
ជាពិសេសគឺបញ្ហាឆាកជីវិតរបស់អ្នកមិញផ្ទាល់តែម្តង។ដូច្នេះរាល់ការសម្ភាសន៍ថ្ងៃនេះ ក្ញុយសុំអនុញ្ញាតអ្នកមិញដើម្បីធ្វើការថតទុកសំលេងអ្នកមិញយកទៅរក្សារទុកនៅសកលវិទ្យាល័យ ប៊ីវ៉ាយយ៉ូ សហរដ្ឋអាមេរិក។ដូច្នេះការសម្ភាសន៍នៅថ្ងៃនេះគឺធ្វើឡើងនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៨ ។សូមអធ្យាស្រ័យ អ្នកមិញមានឈ្មោះអ្វីដែរ?

ខ៖ ស៊ុំ លន
ក៖ អ្នកមិញមានឈ្មោះហៅក្រៅដែររឺទេអ្នកមិញ?
ខ៖ ឈ្មោះក្រៅអត់មានផង។
ក៖ អ្នកមិញមានអាយុប៉ុន្មានដែរ?
ខ៖ មានអាយុ ៥៣ ឆ្នាំ។
ក៖ អ្នកមិញនៅចាំឆ្នាំកំណើតរបស់អ្នកមិញ ដែររឺទេ?
ខ៖ ប្រហែល ១៩៦៦។
ក៖ អ្នកមិញនៅចាំទីកន្លែងកំណើតរបស់អ្នកមិញនៅទីណាដែរ?
ខ៖ ខេត្ត ព្រៃវែង។
ក៖ នៅ ភូមិ ឃុំ អ្វីដែរអ្នកមិញ?
ខ៖ នៅ ភូមិ ផ្លូវលួស ឃុំ ជើងភ្នំ ស្រុកបាភ្នំ ខេត្តព្រៃវែង។
ក៖ បាទ!ពាក់ព័ន្ធនិងសមាជិកគ្រួសាររបស់អ្នកមិញវិញ អ្នកមិញមានបងប្អូនប៉ុន្មានអ្នកដែរ?
ខ៖ បងប្អូនមាន៥នាក់។
ក៖ អ្នកមិញជាកូនទីប៉ុន្មានដែរ?

ខ៖ ជាកូនទី១
ក៖ អ្នកមិញនៅចាំឈ្មោះប្អូនៗរបស់អ្នកមិញមានឈ្មោះអ្វីដែរអ្នកមិញ!
ខ៖ ប្អូនខ្ញុំឈ្មោះ ស៊ុំ ភើន, ស៊ុំ ឌឿន, ស៊ុំ ណាង, ស៊ុំ ណាន់។
ក៖ បាទ!អ្នកមិញមានចងចាំសាច់រឿងរបស់ពួកគាត់ខ្លះៗ ដែររឺទេ អ្នកមិញ?
ពាក់ព័ន្ធកាលនៅពីក្មេង! អ្នកមិញចូលចិត្តលេងអ្វីជាមួយពួកគាត់?
ខ៖ ចាស!ចូលចិត្តលេងបិទពួនជាមួយពួកគាត់យប់ៗ និងជាមួយអ្នកជិតខាង។
ក៖ មានអ្វីទៀតដែររឺទេអ្នកមិញ?
ខ៖ អត់លេងអីទេ លេងតែបិទពួននិង ចូលចិត្តសប្បាយពេលយប់ខែភ្លឺ។
ក៖ បាទ!
ក៖ ពាក់ព័ន្ធនិងឪពុកម្តាយរបស់អ្នកមិញវិញ តើឪពុកម្តាយរបស់អ្នកមិញមានឈ្មោះអ្វីដែរ?
ខ៖ ម្តាយឈ្មោះ ស៊ុំ លៀង ឪពុកឈ្មោះ សួន ផ្ទ។
ក៖ ពួកគាត់ទាំងពីរមានអាយុប៉ុន្មានដែរអ្នកមិញ?
ខ៖ ម្តាយខ្ញុំអាយុ ៧៧ រីឯឪពុកឈ្មោះ គាត់ស្លាប់បាត់ហើយ។
ក៖ បាទ!ចុះអ្នកមិញមាននៅចាំឆ្នាំកំណើតពួកគាត់ទាំងពីរដែររឺទេ?
ខ៖ អត់ផង
ក៖ ចុះពួកគាត់កើតនៅសម័យណាដែរ?
ខ៖ មិញមិនចាំដែរ។
ក៖ ចុះស្រុកកំណើតពួកគាត់នៅឯណាដែរអ្នកមិញ?
ខ៖ នៅជាមួយគ្នា។

ក៖ នៅឯណាដែរអ្នកមិញ?
ខ៖ នៅព្រៃវែង។ ភូមិ ផ្លូវលួស ឃុំ ជើងភ្នំ ស្រុកបាភ្នំ ខេត្តព្រៃវែង។
ក៖ ទីលំនៅបច្ចុប្បន្នអ្នកមិញនៅទីណាដែរអ្នកមិញ?
ខ៖ បច្ចុប្បន្នខ្ញុំមករស់នៅភ្នំពេញ តែរស់នៅផ្ទះជួល។
ក៖ ចុះផ្ទះជួលស្ថិតនៅ ភូមិ ឃុំ អ្វីដែរអ្នកមិញ?
ខ៖ ដឹងថា ភូមិសន្សំកុសល តែមិនច្បាស់ថា សន្សំកុសល១ ឬ ២។
ក៖ ភូមិសន្សំកុសល ខណ្ឌ មានជ័យ រាជធានីភ្នំពេញ មែនអ្នកមិញ?
ខ៖ ចាស។
ក៖ អ្នកមិញ!ឪពុក អ្នកមិញកាលដែលគាត់នៅមានជីវិត តើគាត់ប្រកបរបរអ្វីដែរ?
ខ៖ គាត់ធ្វើប្រធានភូមិ។ ហើយគាត់ទៅធ្វើពលករវគ្គពីរ
    មកវិញក៏មានជំងឺគ្រុនចាញ់ស្លាប់ទៅ ស្លាប់តាំងពីឆ្នាំ ៩៦ នោះ។
ក៖ បាទ!
ក៖ ចុះអ្នកមិញមើលតាមអត្តចរិករបស់គាត់ គាត់ជាមនុស្សដូចម្តេចដែរ?

ខ៖ គាត់ស្លូតបូត ចេះស្រឡាញ់កូនចៅ រកប្រាក់ចិញ្ចឹមកូនចៅ គាត់ជាជាង ទូរទស្សន៍
ម៉ាញ៉ូ វិទ្យុ ។
ក៖ បាទ! ចុះម្តាយអ្នកមិញវិញ? គាត់ប្រកបមុខរបរអ្វីដែរអ្នកមិញ?
ខ៖ ម្តាយខ្ញុំគាត់មើលកូន ធ្វើស្រែ។
ក៖ ចុះអ្នកមិញមើលតាមអត្តចរិករបស់គាត់ គាត់ជាមនុស្សដូចម្តេចដែរ?
ខ៖ គាត់ស្លូត មិនចេះជេរកូនចៅទេ។គាត់ពិតជាស្លូតខ្លាំងណាស់។
ក៖ ចុះអ្នកមិញ!គាត់មានដែលនិយាយប្រាប់ រឺនិទានរឿងអោយអ្នកមិញស្តាប់ដែររឺទេ?
ខ៖ អត់ផង។
ចុះអ្នកមិញ មានធ្លាប់លឺចាស់ៗ ឬ អ្នកជិតខាងនិយាយពីរប្រវត្តិរបស់គាត់ដែររឺទេអ្នកមិញ?
ខ៖ អត់ផង។
ក៖ បាទ!ចុះពាក់ព័ន្ធនិងជីដូនជីតារបស់អ្នកមិញវិញ
អ្នកមិញមាននៅចាំឈ្មោះពួកគាត់ទាំងខាងឪពុកនិងម្តាយដែររឺទេ អ្នកមិញ?
ខ៖ ចាំ
ក៖ ឈ្មោះអ្វីដែរអ្នកមិញ?
ខ៖ តាឈ្មោះ ស៊ុ ខ្ញុំភ្លេចត្រកូលរបស់គាត់បាត់ហើយ ឯយាយឈ្មោះ លឹម។
ក៖ ខាងណាដែរអ្នកមិញ?
ខ៖ និងខាងម្តាយ។ ឯខាងឪពុកឈ្មោះ សួន ឯយាយឈ្មោះ យាយ អាច។
ក៖ បាទ!ចុះអ្នកមិញមានចាំឆ្នាំកំណើតពួកគាត់ដែររឺទេអ្នកមិញ?
ខ៖ អត់ចាំទេ។
ក៖ ចុះអ្នកមិញមានធ្លាប់ដឹងរឿងរបស់ពួកគាត់
ដូចជាធ្លាប់ឪពុកម្តាយអ្នកមិញនិទានអោយស្តាប់ជាដើម មានធ្លាប់អត់អ្នកមិញ?
ខ៖ អត់ដែលផង។
ក៖ បាទ!ចុះអ្នកមិញរស់នៅទីរួមខេត្តនិងអស់រយៈពេលប៉ុន្មានឆ្នាំដែរ?
ខ៖ រស់នៅតាំងពីកើតមក រហូតមកទាល់ឥឡូវអត់ដែលផ្លាស់ប្តូរផង។
ក៖ ចុះអ្នកមិញមានធ្លាប់លឺថាមានបងប្អូននៅក្រៅប្រទេសដែររឺទេអ្នកមិញ?
ខ៖ អត់មានផង។បងប្អូនខ្ញុំនៅស្រុកខ្មែរទាំងអស់។
ក៖ ចុះអ្នកមិញ! ពាក់ព័ន្ធរឿងអាពាហ៍ពិពាហ៍របស់អ្នកមិញវិញ
អ្នកមិញមានស្វាមីឈ្មោះអ្វី?
ខ៖ គាត់ឈ្មោះ លុក ខេរ។
ក៖ ចុះអ្នកមិញរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅឯណាដែរ?

ខ៖ នៅព្រៃវែង។
ក៖ ចុះអ្នកមិញនៅចាំថ្ងៃ ខែ ដែលរៀបអាពាហ៍ពិពាហ៍ដែររឺទេ?
ខ៖ ដឹងតែឆ្នាំ ១៩៩០ អ៊ុនតាក់ចូលស្រុក ក្រៅពីនិងមិនចាំទេ។

ក៖ ចុះការរៀបចំអាពាហ៍ពិពាហ៍និង នណារអ្នករៀបចំអោយដែរអ្នកមិញ?
ខ៖ ដោយឪពុកម្តាយទាំងសងខាង។
ក៖ ចុះអ្នកមិញនៅចាំថ្លៃបណ្តាការដែររឺទេអ្នកមិញ?
ខ៖ កាលនិងបានតែមួយម៉ឺនទេ។ព្រោះសម័យនិងចំណងដៃបានតែ ពីររយ បីរយ
តែប៉ុណ្ណោះ ខ្ពស់បំផុត ប្រាំរយ។ភ្លេងការ ប្រាំរយ ផ្ទ្ធងការ មួយពាន់ប្រាំរយ។
ក៖ ចុះកាលនិងគេចងដៃជាលុយដែរមិញ?
ខ៖ ចាស ចងលុយ។
ក៖ ចុះពេលអ្នកមិញជួបស្វាមីដំបូង ជួបគ្នាតាមរយៈណាដែរ
ហើយនៅចាំអនុស្សាវីយ៍ខ្លះៗដែរឬទេអ្នកមិញ?
ខ៖ ស្គាល់គ្នា ព្រោះត្រូវជាបងប្អូន តែសាច់ឆ្ងាយដែរហើយខាងឪពុក។
ក៖ ជួបគ្នាដំបូងដូចម្តេចដែរ អ្នកមិញ?
ខ៖ ជួបដំបូងគេស្រលាញ់មិញ តែមិញអត់ស្រលាញ់។ទាល់ឪពុកម្តាយបង្ខំ
ហើយក៏ព្រមការ រស់នៅមកទាល់ឥឡូវទៅ។
ក៖ តើគាត់ធ្វើដូចម្តេចខ្លះ គាត់ចេះតែមកសុំឪពុកម្តាយអ្នកមិញមែន? អ្នកមិញ!
ខ៖ ចាស។គាត់ចេះតែមកសុំម្តាយខ្ញុំ ហើយម្តាយខ្ញុំចេះតែមកបង្ខំខ្ញុំ។
ក៖ ពាក់ព័ន្ធនឹងភាសារខ្មែរ អ្នកមិញចេះអាន ចេះសរសេរដែររឺទេ អ្នកមិញ?
ខ៖ ចេះសរសេរធម្មតា។
ក៖ អ្នកមិញមានចេះអ្វីក្រៅពីភាសារខ្មែរដែរឬទេអ្នកមិញ?
ខ៖ អត់ផង។ រៀនបានត្រឹមថ្នាក់ទី៥ ឪពុកខ្ញុំឈឺខ្ញុំក៏ឈប់រៀន។

ក៖ បាទ! ចុះសាលាអ្នកមិញនៅណាដែរ?
ខ៖ នៅឈើកាច់។
ក៖ ឈ្មោះអ្វីដែរអ្នកមិញសាលានិង?
ខ៖ សាលាបឋមសិក្សារឈើកាច់។
ក៖ ចុះកំឡុងពេលដែលសិក្សារអ្នកមិញមានមិត្តជិតស្និតអត់?
ខ៖ ចាស អតើមានផងគ្រាន់តែរាប់អានគ្នាធម្មតា។
ក៖ អត់មានស្និតស្នាលទេអ្នកមិញ?
ខ៖ អត់។
ក៖ អ្នកមិញនៅចាំឈ្មោះពួកគាត់អត់?
ខ៖ ឈ្មោះ ស្រឿន និង ចាន់ណា ។មានតែពីអ្នកនិងទេ។
ក៖ អ្នកមិញមានចាំសាច់រឿងពួកកាត់ខ្លះៗអត់ ពួកគាត់ពួកគាត់ជាមនុស្សបែបណា?
ខ៖ ពួកគាត់ជាមនុស្សរៀនពូកែ ទទួលបានចំណាត់ថ្នាក់ ក្នុងនោះក៏មានខ្ញុំដែរ។
ក៖ បន្ទាប់ពីការសិក្សារនៅថ្នាក់ទី៥ តើអ្នកមិញប្រកបមុខរបរការងារអ្វីដែរ?

ខ៖ នៅផ្ទះមើលប្អូនព្រោះឪពុកឈឺ មិនបានប្រកបរបរអ្វីទេ
គាត់ត្រូវទៅសំរាកនៅពេទ្យឯព្រៃវែង។
ក៖ ពាក់ព័ន្ធនិងឆាកជីវិតអ្នកមិញវិញ តាំងពីក្មេងមកដល់ពេលនេះ
មានការផ្លាស់ប្តូរអ្វីខ្លះដែរអ្នកមិញ?
ខ៖ ពីមុនរៀងក្រលំបាក តែឥឡូវរៀងធូរធារ មានលុយកាក់សល់ខ្លះ
និងមិនបាច់ដើរខ្ចីគេ។ពីមុនរាងលំបាកទម្រាំដល់ថ្ងៃនេះ។
ក៖ ពាក់ព័ន្ធនិងម្ហូបវិញ!អ្នកមិញចូលចិត្តបរិភោគម្ហូបអ្វីដែរអ្នមិញ?
ខ៖
ចូលចិត្តសាច់ត្រីជាងគេ។ព្រោះសាច់ត្រីហូបទៅសុខភាពល្អ។បើសាច់ហូបទៅនាំអោយចុកដៃជើង លើសអាស៊ីតទៀត ចឹងហើយបានអត់ស្ងូវចូលចិត្ត។

ក៖ ត្រីនិងអ្នកមិញចូលចិត្តយកទៅអាំងឬស្ល?
ខ៖ យកទៅអាំង ទៅស្ល គ្រប់មុខបានទាំងអស់។
ក៖ បាទ!ចុះអ្នកមិញពាក់ព័ន្ធនិងល្បែងលេងវិញ
តាំងពីក្មេងមកទល់ពេលនេះអ្នកមិញចូលចិត្តលេងអ្វីជាងគេ?
ខ៖ ចូលចិត្តលេង លេងឈ្លូស លេងម៉ឹក កូនកូលអីជាដើម។
ពេលល្ងាចឡើងមកពីមើលគោរវិញនាំគ្នាលេងដូចជា ឈ្លូសម៉ឹក កូនកូលអីនិង
ជាល្បែងប្រចាំការ។
ក៖ ចុះអ្នកមិញជិតចូលឆ្នាំចឹង
អ្នកមិញមមានចូលចិត្តលេងល្បែងប្រជាប្រិយអ្វីដែរអ្នកមិញ?
ខ៖ ពីមុនចូលចិត្តលេងឈ្លូង ចោះអង្គញ់ ពេលចូលឆ្នាំម្តងៗសប្បាយណាស់
តែឥលូវចាស់ហើយបានតែអង្គុយមើលគេម្តង។
ក៖ ពាក់ព័ន្ធនិងចំរៀង អ្នកមិញចូលចិត្តចំរៀងអ្វីជាងគេដែរ?
ហើយបទសម័យណាដែលអ្នកមិញចូលចិត្ត?
ខ៖ ចូលចិត្ត ស៊ិន ស៊ីសាមុត និង រស់សេរី សុទ្ធា ។
ក៖ ចុះបទណាដែលអ្នកមិញចូលចិត្តជាងគេរហូតដល់ចេះច្រៀង?
ខ៖ អត់ចេះ ចេះតែស្តាប់ ពិរោះក៏ស្តាប់ទៅ អត់ដែលចេះច្រៀងផង។
ក៖ ពាក់ព័ន្ធនិងសមាជិកគ្រួសារអ្នកមិញកាលពីមុន តើមានណារដែលចេះលេង ភ្លេង ឬ
ឧបករណ៍តន្ត្រីខ្មែរ ចេះសម្តែង ល្ខោនបាសាក់ យីកេ រ៉ូ ធ្លាប់មានដែររឺទេអ្នកមិញ?
ខ៖ ដូចជាអត់មានផង ចេះតែរកទទួលទាន ធ្វើស្រែចំការ
អត់ដែលមានអ្នកចេះខាងនិងផង។
ក៖ ពាក់ព័ន្ធនិងអត្តចរិតផ្ទាល់របស់អ្នកមិញវិញ តាំងពីក្មេងមកទល់ពេលនេះ
អ្នកមិញជាមនុស្សបែបណាដែរ?
ខ៖ ជាមនុស្សសាមញ្ញធម្មតា មិនក្រអើតក្រទម។

 ក៖
បាទ!ចុះអ្នកមិញមានចងចាំរូបរាងផ្ទះរបស់អ្នកមិញកាលនៅស្រុកមានរូបរាងបែបណាដែរអ្នកមិញ?
 ខ៖ ផ្ទះឆេះអស់ហើយ
កាលពីបោះឆ្នោតលើដំបូងនៅស្រុកយើង។ហើយក៏បានផ្លាស់ទីលំនៅមកភ្នំពេញតែម្តងមកទល់ឥឡូវមិនទាន់មានផ្ទះនៅវិញផង។
 ក៖ ចុះផ្ទះអ្នកមិញមាននៅចាំរូបរាងផ្ទះខ្លះទេអ្នកមិញ?
 ខ៖ ផ្ទះស្លឹក ទទឹង៤ម៉ែត បណ្តោយ៥ម៉ែត ជញ្ជាំងស្លឹក ដំបូលស្លឹក រនាបឬស្សី ឆេះម៉ោង៥ល្ងាច។
 ក៖ ចុះផ្ទះនិងនណារអ្នកធ្វើដែរ?
 ខ៖ ផ្ទះនិងជួលគេធ្វើ។
 ក៖ ចុះអ្នកមិញមានចេះជំនាញអ្វី ដែលចេះបន្តពីរឪពុកម្តាយដូចជា ត្បាញ ធ្វើម្ហូប រឺជំនាញអ្វីផ្សេងទៀត?
 ខ៖ មានតែចេះដូចជា ដាំបាយ ធ្វើម្ហូបជាដើម ចេះតិចតួច គ្រាន់តែ ចៀន ស្ងោរឆា អីជាដើម។
 ក៖ ចូលដល់ឆាកជីវិតរបស់អ្នកមិញវិញ
តើអ្នកមិញធ្លាប់ឆ្លងកាត់បញ្ហារលំបាកអ្វីខ្លះដែរអ្នកមិញ?
 ខ៖ ជួបការលំបាកដូចជាបញ្ហារសុខភាព ព្រោះនៅហូបថ្នាំរាល់ថ្ងៃ ទៅពេទ្យតែពីអ្នកប្តីប្រពន្ធគ្មានបងប្អូនណាមកមើលទេ។
 ក៖ អ្នកមិញមានជំងឺអ្វីដែរអ្នកមិញ?
 ខ៖ ១បេង លូវលេបថ្នាំបាន៧ខែហើយ។
 ក៖ អ្នកមិញមានធ្លាប់បានឆ្លងកាត់សម័យ ពលពត ដែររឺទេ អ្នកមិញ?
 ខ៖ ចាសបានឆ្លងកាត់កាកនិងខ្ញុំនៅតូច ខ្ញុំអាយុជាង១០ឆ្នាំ។
 ក៖ កាលសម័យនិងអ្នកមិញធ្លាប់ឆ្លងកាត់ការលំបាកអ្វីខ្លះដែរអ្នកមិញ?
 ខ៖ កាលនិងគេអោយទៅនៅមណ្ឌល ហូបបាយអត់ឆ្អែត មិនអោយជួបឪពុកម្តាយ ថ្ងៃណាអត់ម្ហូបហូបអំបិល ចាស់ៗហូបសម្ល ព្រោះគាត់ត្រូវធ្វើការ។
 ក៖ កាលគេជំលៀសអ្នកមិញ គេជំលៀសពីណារទៅណា?
 ខ៖ ពីព្រៃវែង ទៅ មូងមានជិតមួយឆ្នាំដែរកាលនិង
និយាយរួមទៅគ្រប់កន្លែងនិងនេះតិចនៅតិច។
 ក៖ កាលនិងគេមានប្រើអោយអ្នកមិញធ្វើការអ្វីទេ?
 ខ៖ គេប្រើអោយបោចស្មៅស្រូវ និង
ទូលជីដាក់ស្រែ។ព្រោះកាលនិងនៅតូចចឹងគេប្រើស្រាលៗ តែទូលជីទៅឆ្ងាយណាស់ មួយព្រឹកបានតែមួយជើងទេ គ្រាន់តែទៅហើយមកវិញដល់ម៉ោងបាយ។

ក៖ ទាក់ទងនិងបទពិសោធន៍ល្អៗ
ក្នុងជីវិតដែលធ្វើអោយអ្នកមិញសប្បាយចិត្តមានរឿងអ្វីខ្លះដែរ អ្នកមិញ?
ខ៖ មានលុយមានកាក់ដូចឥលូវ គ្រាន់ថាយើងចាស់ទៅវាលំបាក វាមិនដូចពីមុនទេ
ឥលូវសប្បាយរហូតត្រង់មិនជំពាក់គេ មានលុយដើរលេងបាន
គ្រាន់មិនដែលបានទៅណាឆ្ងាយ។
ក៖ ចុះអ្នកមិញមានចង់ទៅដើរលេងទៅណាដែររឺទេអ្នកមិញ?
ខ៖ ចង់តាស!ចង់ទៅសៀមរាប ចង់ទៅកំពង់សោម ព្រោះមិនដែលស្គាល់។

ក៖ ចុះកាលអ្នកមិញនៅក្មេង អ្នកមិញធ្លាប់មានបំណងប្រថ្នាអ្វីដែរ អ្នកមិញ? ដូចជាធ្វើជាគ្រូពេទ្យ គ្រូបង្រៀន ដែររឺទេអ្នកមិញ?
ខ៖ អត់ធ្លាប់ផង
ក៖ ចឹងបំណងប្រាថ្នា គឺចង់ទៅដើរលេងមែនអត់អ្នកមិញ។
ខ៖ ចាស។ ចាស់ហើយចង់ដើរលេងអោយស្គាល់ម្តង។
ក៖ បាទ!តើអ្នកមិញមានកូនប៉ុន្មានអ្នកដែរ អ្នកមិញ?
ខ៖ អត់មានផង។ មានតែកូនក្មួយ។
ក៖
បាទអ្នកមិញ!ចឹងជាចុងក្រោយតើអ្នកមិញមានជាការផ្តាំផ្ញើរអ្វីទៅកាន់កូនក្មួយជំនាន់ក្រោយខ្លះអ្នកមិញ?
ខ៖ ចុងក្រោយជូនពរអោយកូនៗ ចៅៗ ក្មួយៗ រកស៊ីមានបាន
មានលុយដើរលេងគ្រប់ប្រទេសសប្បាយ។
ក៖ បាទ!ចឹងអរគុណច្រើនអ្នកមិញដែលអ្នកមិញយល់ព្រម
អោយក្មួយបានធ្វើការសម្ភាសន៍នៅថ្ងៃនេះ។
ខ៖ ចា។